Khmer | ភាសាខ្មែរ

# ដឹងអំពីហានិភ័យនៃ រលកយក្សស៊ូណាមិរបស់អ្នក

## ស្វែងយល់អំពីហានិភ័យរលកយក្សស៊ូណាមិរបស់អ្នក

ទាក់ទងអង្គភាព NSW SES នៅតាមតំបន់របស់អ្នកដើម្បីទទួលបានព័ត៌មានអំពីរលកយក្សស៊ូណាមិនៅតាមតំបន់។

ដឹងពីតំបន់ជម្លៀសរលកយក្សស៊ូណាមិ ដោយពិនិត្យមើលឡើងវិញ **ផែនទីតំបន់ជម្លៀង Evacuation Area Map** នៅលើ គេហទំព័រ NSW SES។



### ដឹងអំពីសញ្ញា និងផលវិបាកនៃរលកយក្សស៊ូណាមិ

មានសញ្ញាធម្មជាតិជាច្រើននៃរលកយក្សស៊ូណាមិ ឧទាហរណ៍៖

- រញ្ជួយដី
- អាការៈសមុទ្រមិនធម្មតា៖ មើលទៅដូចជាទឹកជំនន់ដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស ឬជញ្ជាំងទឹក ឬកម្រិតទឹកសមុទ្រធ្លាក់ចុះយ៉ាងខ្លាំងរហូតដល់បង្ហាញឃើញបាតសមុទ្រ
- សំឡេងរន្ទឺខ្លាំងចេញពីមហាសមុទ្រ ស្រដៀងនឹងសំឡេងរថភ្លើង

## រៀបចំកញ្ចប់សង្គ្រោះបន្ទាន់

កញ្ចប់សង្គ្រោះបន្ទាន់របស់អ្នកត្រូវតែមាន៖

- វិទ្យុចល័តដែលមានថ្មបម្រុងទុក
- ពិលដែលមានថ្មបម្រុង
- កញ្ចប់សង្គ្រោះបឋម (ជាមួយនឹងការផ្គត់ផ្គង់ចាំបាច់សម្រាប់គ្រួសាររបស់អ្នក)
- ទៀន និងឈើគូសមិនជ្រាបទឹក
- ឯកសារសំខាន់ៗ រួមមាន លេខទូរសព្ទទំនាក់ទំនងក្នុងគ្រាអាសន្ន
- ច្បាប់ចម្លងនៃផែនការសង្គ្រោះបន្ទាន់ទាំងអស់
- ថង់មិនជ្រាបទឹកសម្រាប់ដាក់វត្ថុមានតម្លៃ។

## ត្រៀបជាស្រេច




ទាញយកកម្មវិធី **គ្រោះថ្នាក់នៅជិតខ្ញុំ (Hazards Near Me app)** លទៅក្នុងឧបករណ៍ចល័តរបស់អ្នក ហើយបង្កើត **តំបន់ឃ្លាំមើល** សម្រាប់តំបន់នានាដែលអ្នករស់នៅ ធ្វើការ និងទៅលេង។



រៀបចំ **ផែនការជម្លៀសរលកយក្សស៊ូណាមិ** សម្រាប់ផ្ទះ អាជីវកម្ម និងទ្រព្យសម្បត្តិរបស់អ្នកដែលស្ថិតនៅក្នុងតំបន់ដែលមានហានិភ័យរលកយក្សស៊ូណាមិ ហើយត្រូវធ្វើឱ្យប្រាកដថាអ្នករៀបចំផែនការសម្រាប់មនុស្ស និងសត្វទាំងអស់ដែលស្ថិតនៅក្នុងការថែទាំរបស់អ្នក។



ចែករំលែកផែនការសង្គ្រោះបន្ទាន់របស់អ្នកជាមួយគ្រួសារ អ្នកជិតខាង និងសហការី ហើយពិនិត្យវាឡើងវិញជាប្រចាំ។

ក្នុងស្ថានភាពគំរាមកំហែងដល់អាយុជីវិត ហៅទូរសព្ទទៅ **លេខសូន្យបីដង (000)**

សម្រាប់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ទឹកជំនន់ ព្យុះភ្លៀង និងរលកយក្សស៊ូណាមិ សូមហៅទូរសព្ទទៅ **NSW SES** តាមលេខ **132 500**។

**www.ses.nsw.gov.au/languages**

@NSWSES NSWSES NSWSES